ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

* * *

ឆ្នាំទី ៣ លេខ ៤៣ ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

រាជកិច្ច

រួមមាន :

- ច្បាប់
- ក្រម-ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្តីសំរេច
- សារាចរ

ផ្សាយចេញពីទីស្តីការគណៈរដ្ឋមន្ត្រីរៀងរាល់សប្តាហ៍

មាតិកា

I .ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

១៨-១១-១៩៩៥	-ព្រះរាជក្រម លេខ នស/រកត/១១៩៥/៨០ តែងតាំងជំទាវ **ស៊ុំ នីផា** ជាអគ្គទេសាភិបាលរងធនាគារជាតិកម្ពុជា	២១៩០
១៨-១១-១៩៩៥	-ព្រះរាជក្រឹត្យលេខ នស / រកត /១១៩៥/៨១ តែងតាំងជំទាវ ប៉ែនត្រីស្ទីន ជានាយកពិធីការសម្តេចក្រុមព្រះនាយករដ្ឋមន្ត្រីទី ១	២១៩១
១៨-១១-១៩៩៥-	ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៥/៨២ តែងតាំងឯកឧត្តម **ភខ ឈឹម** ជាទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រីទី ២	២១៩២
១៨-១១-១៩៩៥-	ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៥/៨៣ តែងតាំងឯកឧត្តម **ផុន សុផល** ជាអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានអធិការកិច្ច រាជរដ្ឋាភិបាល	២១៩៣
១៨-១១-១៩៩៥-	ព្រះរាជក្រឹត្យលេខ នស/រកត/៨៤ តែងតាំងឯកឧត្តម **លឹម គានហោ** ជាអគ្គនាយកធារាសាស្ត្រ ឧតុនិយម និង ជលសាស្ត្រ	២១៩៤
២២-១១-១៩៩៥-	ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៥/៨៦ តែងតាំងលោក **ឡូង ឃ្លោះ** ជាទីប្រឹក្សារបស់រាជរដ្ឋាភិបាល	២១៩៥

២២-១១-១៩៩៥- ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៥/៨៧ តម្លើង
ឋានន្តរសក្តិថ្នាក់ឧត្តមសេនីយ៍ត្រី ជាកិច្ចបច្ឆាមរណៈ
ជូនចំពោះសព លោកវរសេនីយ៍ឯក មុំ សាវី ២១៩៦

II . ទីស្តីការគណៈរដ្ឋមន្ត្រី

១ - អនុក្រឹត្យ

៣០-១១-១៩៩៥-អនុក្រឹត្យលេខ ៨៤ អនក្រ. ស្តីពីប្រតិទិនឈប់សំរាកការ
ងាររបស់មន្ត្រីរាជការ និយោជិក កម្មករ ប្រចាំឆ្នាំ១៩៩៦ ២១៩៧
២៨-១១-១៩៩៥-អនុក្រឹត្យលេខ ១២៣ អនក្រ. តត ស្តីពីការតែងតាំងមន្ត្រី
រាជការ ២១៩៩
២៨-១១-១៩៩៥-អនុក្រឹត្យលេខ ១២៤ អនក្រ. តត ស្តីពីការជូនមេដាយ
មន្ទីសារភ័ណ្ឌ ២២០០
៣០-១១-១៩៩៥-អនុក្រឹត្យលេខ ១២៥ អនក្រ. តត ស្តីពីការជូនមេដាយ
ស្ថាបនាជាតិ ២២០១
៣០-១១-១៩៩៥-អនុក្រឹត្យលេខ ១២៦ អនក្រ. តត ស្តីពីការតែងតាំង
មន្ត្រីរាជការ ២២០២

២ - សេចក្តីសំរេច

២៩-១១-១៩៩៥-សេចក្តីសំរេចលេខ ៨០ សសរ ស្តីពីការផ្ទេរសិទ្ធិ ២២០៣
២៩-១១-១៩៩៥-សេចក្តីសំរេចលេខ ៨១ សសរ ស្តីពីការផ្ទេរសិទ្ធិ ២២០៤
២៩-១១-១៩៩៥-សេចក្តីសំរេចលេខ ៨២ សសរ ស្តីពីការបង្កើតគណៈកម្ម
ការពិគ្រោះ ពិភាក្សាធ្វើឯកជនភាវូបនីយកម្មចំការកៅស៊ូជប់
និងក្រែកជាមួយភាគី TERRES ROUGES ២២០៥

III - ការចារបណ្ណាក្រសួង

១ - ទីស្ដីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ប្រកាស

២៣-១១-១៩៩៥- ប្រកាសលេខ ៣៩២ ប្រក. សហវ. ថ ស្ដីពីការបង្វែរឥណទាន ២២០៧

២៣-១១-១៩៩៥- ប្រកាសលេខ ៣៩៣ ប្រក. សហវ. ថ ស្ដីពីការបង្វែរឥណទាន ២២១០

២៩-១១-១៩៩៥- ប្រកាសលេខ ៤១៥ ប្រក សហវ. ថ ស្ដីអំពីការបង្វែរឥណទាន ២២១២

២- ទីស្ដីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

ប្រកាស

២៣-១១-១៩៩៥- ប្រកាសលេខ ៨៣៦ ឧក. ប្រក អនុញ្ញាតអោយលោក **ឈុន អេង** ជនជាតិខ្មែរ បើកដំណើរការសហគ្រាសផលិតគ្រឿងសង្ហារឹម ២២១៤

២៤-១១-១៩៩៥- ប្រកាសលេខ ៨៣៨ ឧក. ប្រក អនុញ្ញាតអោយលោក **ស្រ៊ុន ម៉ិរ** ជនជាតិខ្មែរ បើកដំណើរការរោងជាងផលិតគ្រឿងសង្ហារឹម ២២១៥

២៤-១១-១៩៩៥- ប្រកាសលេខ ៨៤០ ឧក. ប្រក អនុញ្ញាតអោយលោក **សុខ ឃួរ** ជនជាតិខ្មែរ ម្ចាស់ឡឥដ្ឋគៀង ផ្ទេរភារកិច្ចគ្រប់គ្រងជូនអ្នកស្រី **សាម៉ីឌី សូលីនដា** វិញ ២២១៦

២៥-១១-១៩៩៥- ប្រកាសលេខ ៨៤២ ឧក. ប្រក អនុញ្ញាតអោយលោក CITY NEWGARMENT FACTORY (CAMBODIA) CO LID ដំណើរការផលិតកម្ម អាជីវកម្មរោង ចក្រកាត់ដេរសំលៀកបំពាក់ ២២១៧

៣ - ទីស្តីការរដ្ឋមន្ត្រីក្រសួងពត៌មាន

ប្រកាស

៣០-១១-១៩៩៥- ប្រកាសលេខ ២៩០/៩៥ ពម.ប្រក អនុញ្ញាតអោយលោក
ម៉ូយ កោសល្យ បើកអាជីវកម្មរោងពុម្ពឈ្មោះ «ពន្លឺរស្មី» ២២១៩

៤ - ទីស្តីការរដ្ឋមន្ត្រីក្រសួងផែនការ

ប្រកាស

២៨-១១-១៩៩៥- ប្រកាសលេខ ១២៨ ផ.ក ស្តីពីការបង្កើតការិយាល័យ
វិនិយោគសាធារណៈ ២២២០

៥ - ទីស្តីការក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

ប្រកាស

២៤-១១-១៩៩៥- ប្រកាសលេខ ១៧៥ បទ.ប្រក ស្តីពីថ្លៃប្រើប្រាស់បរិបទ
ទិន្នន័យក្នុងប្រទេស ២២២២

I - ខុទ្ទកាល័យព្រះមហាក្សត្រ

១ - ព្រះរាជក្រឹត្យ

ព្រះរាជក្រឹត្យ លេខ នស.រកត ១១៩៥/៨០

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាព រាជរដ្ឋាភិបាលកម្ពុជា
- យោងតាមសំណើរបស់នាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលជាតិកម្ពុជា ចុះថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងលោកជំទាវ **ស៊ុំ នីផា** ជាអគ្គទេសាភិបាលរងធនាគារជាតិកម្ពុជា ជំនួសតួនាទី បច្ចុប្បន្នរបស់លោកស្រី **ជុំ សុម៉ូរ៉ា** ។

មាត្រា ២ : នាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្ត អោយបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានច្បាប់ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

ព្រះហស្តលេខា

នរោត្តម សីហនុ

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

ព្រះរាជក្រឹត្យ លេខ នស.រកត ១១៩៥/៨១

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័នរាជមហាវិទ្ធ្យ

ឧត្តមោសុជាត វិសុទ្ធពង្សអគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- យោងតាមសំណើរបស់នាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលជាតិកម្ពុជា ចុះថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

ប្រកាសបន្ទាប់

មាត្រា ១ : តែងតាំងឯកឧត្តម **ម៉ែន គ្រីស្នែន** ជានាយកកិច្ចការសម្តេចក្រុមព្រះនាយករដ្ឋមន្ត្រីទី១ នៃរាជ រដ្ឋាភិ ា រកម្ពុជា មានឋានៈស្មើអនុរដ្ឋលេខាធិការ ។

មាត្រា ២ : នាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្ត អោយ សំរេចតាមព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានច្បាប់ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

ព្រះហស្តលេខា

នរោត្តម សីហនុ

* * *

ព្រះរាជក្រឹត្យ លេខ : ១១៩៥/៨២ នស.រកត

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័នរាជហរិវង្ស

ឧភតោសុជាត វិសុទ្ធពង្សអគ្គមហាបុរសរតនៈ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- យោងតាមសំណើរបស់នាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលជាតិកម្ពុជា ចុះថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

ព្រះរាជក្រឹត្យ

មាត្រា ១ : តែងតាំងឯកឧត្តម **ភាព ឈិនណា** ជាទីប្រឹក្សារបស់សម្តេចនាយករដ្ឋមន្ត្រីទី ២ ទទួលបន្ទុកអធិការកិច្ចមានឋានៈស្មើអនុរដ្ឋលេខាធិការ ។

មាត្រា ២ : នាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្ត អោយបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានច្បាប់ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

ព្រះហស្តលេខា

នរោត្តម សីហនុ

* * *

ព្រះរាជក្រឹត្យ លេខ នស.រកត ១១៩៥/៨៣

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស

ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាព រាជរដ្ឋាភិបាលកម្ពុជា

– យោងតាមសំណើរបស់នាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលជាតិកម្ពុជា ចុះថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងឯកឧត្តម **នុន សុផល** ជាអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានអធិការកិច្ចរាជ រដ្ឋាភិបាល មានបុព្វសិទ្ធិស្មើអនុរដ្ឋលេខាធិការ ។

មាត្រា ២ : នាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានច្បាប់ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

ព្រះហស្តលេខា

នរោត្តម សីហនុ

* * *

ព្រះរាជក្រឹត្យ លេខ : នស.រកត ១១៩៥/៨៤

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស

ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

* * *

– បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

– បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា

– បានឃើញច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

- យោងតាមសំណើរបស់នាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលជាតិកម្ពុជា ចុះថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងឯកឧត្តម **លឹម គានហោ** ជាអគ្គនាយក ធារាសាស្ត្រឧតុនិយម និងជលសាស្ត្រ ។

មាត្រា ២ : នាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្ត អោយបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានច្បាប់ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

ព្រះហស្ថលេខា

នរោត្តម សីហនុ

* * *

ព្រះរាជក្រឹត្យ លេខ នស.រកត ១១៩៥/៨៦

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស

ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

- យោងតាមសំណើរបស់នាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលជាតិកម្ពុជា ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងលោក **ឡុង ឡា** ជាទីប្រឹក្សាច្បាប់របស់រាជរដ្ឋាភិបាល ។

មាត្រា ២ : នាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្ត អោយបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានច្បាប់ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

ព្រះហស្ថលេខា

នរោត្តម សីហនុ

* * *

ព្រះរាជក្រឹត្យ លេខ នស.រកត ១១៩៥/៨៧

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស ឧភតោសុជាត

វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ

បរមបពិត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- យោងតាមសំណើរបស់នាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២ និងសហរដ្ឋមន្ត្រីក្រសួងការពារជាតិ

ព្រះរាជបញ្ញត្តិ

មាត្រា ១ : ត្រូវបានតម្លើង ឋានន្តរសក្តិថ្នាក់ **ឧត្តមសេនីយ៍ត្រី** ជាកិច្ចបញ្ចាមរណៈជូនចំពោះសព លោកវរសេនិយឯក **ម៉ុំ សារី** អត្តលេខ ០០០២៣០ នាយករង នាយកដ្ឋានអធិការកិច្ចទូទៅ ក្រសួងការពារជាតិ ។

មាត្រា ២ : នាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលកម្ពុជា និងជាសហអគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទត្រូវទទួលបន្ទុក អនុវត្តអោយបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានច្បាប់ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

ព្រះហស្តលេខា

នរោត្តម សីហនុ

* * *

II - ទីស្តីការគណៈរដ្ឋមន្ត្រី

១ - អនុក្រឹត្យ

រាជធានីភ្នំពេញ , ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

អនុក្រឹត្យ លេខ : ៨៤ អនក្រ.បក

ស្តីពីប្រតិទិនឈប់សំរាករាជការរបស់មន្ត្រីរាជការ

និយោជិត កម្មករ ប្រចាំឆ្នាំ ១៩៩៦

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ឧត្តមព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

- តាមសំណើរបស់គណៈអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិលេខ ៤៧៩-៩៥ គបជ. ចុះ ថ្ងៃទី ១២-១០-១៩៩៥

សម្រេច

មាត្រា ១ : អនុញ្ញាតអោយមន្ត្រីរាជការ និយោជិក កម្មករ នៃព្រះរាជាណាចក្រកម្ពុជាទាំងអស់ បាន ឈប់សំរាកការងារប្រចាំឆ្នាំ ១៩៩៦ តាមប្រតិទិនខាងក្រោម ÷

ថ្ងៃទី ០១ មករា	ទិវាចូលឆ្នាំសកល	០១ ថ្ងៃ
ថ្ងៃទី ០៨ មីនា	ទិវានារីអន្តរជាតិ	០១ ថ្ងៃ
ថ្ងៃទី ១៣-១៤-១៥ មេសា	បុណ្យចូលឆ្នាំប្រពៃណីជាតិ	០៣ ថ្ងៃ
ថ្ងៃទី ០១ ឧសភា	ទិវាពលកម្មអន្តរជាតិ	០១ ថ្ងៃ
ថ្ងៃទី ០២ ឧសភា	បុណ្យពិសាខបូជា	០១ ថ្ងៃ
ថ្ងៃទី ០៦ ឧសភា	ពិធីច្រត់ព្រះនង្គ័ល	០១ ថ្ងៃ
ថ្ងៃទី ០១ មិថុនា	ទិវាកុមារអន្តរជាតិ	០១ ថ្ងៃ
ថ្ងៃទី ១៨ មិថុនា	ព្រះរាជពិធីបុណ្យចំរើនព្រះជន្មវស្សាសម្តេចព្រះមហេសី **នរោត្តមមុនីនាថ សីហនុ**	០១ ថ្ងៃ
ថ្ងៃទី ២៤ កញ្ញា	ទិវាប្រកាសរដ្ឋធម្មនុញ្ញ និងព្រះរាជពិធីគ្រងរាជ្យសម្បត្តិជាថ្មីរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន**	០១ ថ្ងៃ
ថ្ងៃទី ១១-១២-១៣ តុលា	បុណ្យភ្ជុំបិណ្ឌ	០៣ ថ្ងៃ
ថ្ងៃទី ២៣ តុលា	ទិវាសន្ធិសញ្ញាសន្តិភាពក្រុងប៉ារីស	០១ ថ្ងៃ
ថ្ងៃទី ៣០-៣១ តុលា និង ០១ វិច្ឆិកា	ព្រះរាជពិធីបុណ្យចំរើនព្រះជន្មវស្សាព្រះករុណាព្រះបាទសម្តេចព្រះ**នរោត្តម សីហនុ វរ្ម័ន**	០៣ ថ្ងៃ
ថ្ងៃទី ០៩ វិច្ឆិកា	បុណ្យឯករាជជាតិ	០១ ថ្ងៃ

ថ្ងៃទី ២៤-២៥-២៦ វិច្ឆិកា បុណ្យអុំទូក បណ្តែតប្រទីប
សំពះព្រះខែ អកអំបុក ០៣ ថ្ងៃ
ថ្ងៃទី ១០ ធ្នូ ទិវាសិទ្ធិមនុស្ស ០១ ថ្ងៃ

មាត្រា ២ : ពេលវេលាឈប់ទាំងឡាយណា ដែលត្រូវចំថ្ងៃអាទិត្យត្រូវបានអនុញ្ញាតអោយឈប់សំរាក ០១ ថ្ងៃ នៅថ្ងៃបន្ទាប់ជាបន្ថែម ។

មាត្រា ៣ : បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៤ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីគ្រប់ក្រសួង រដ្ឋលេខាធិការនៃគ្រប់រដ្ឋលេខាធិការដ្ឋាន ត្រូវទទួលអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១ **នាយករដ្ឋមន្ត្រីទី ២**

ព្រះហស្តលេខា និងត្រា **ហត្ថលេខា និង ត្រា**

នរោត្តម រណឫទ្ធិ **ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

អនុក្រឹត្យ លេខ ១២៣ អនក្រ.តត

ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- តាមសំណើរបស់ សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

សំរេច

មាត្រា ១ : តែងតាំងឯកឧត្តម **សំ សុខផល** ជាទីប្រឹក្សាឯកឧត្តម **ម៉េង សុីវុទ្ធ** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងឯកឧត្តម **សំ សុខផល** ត្រូវ អនុវត្តអនុក្រឹត្យនេះដែលចូលជាធរមានចាប់តាំង ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះ ហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១
ព្រះហស្តលេខា និង ត្រា
នរោត្តម រណឫទ្ធិ

នាយករដ្ឋមន្ត្រីទី ២
ហត្ថលេខា និង ត្រា
ហ៊ុន សែន

* * *

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

អនុក្រឹត្យ លេខ : ១២៤ អនក្រ.តត

ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស / រកត / ១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយ មុនីសារាភណ្ឌថ្នាក់ «អស្សរិទ្ធិ »ជូនចំពោះលោកបណ្ឌិត **សៃ មិង យូ** « TSAI MING YU » ដែលមានគុណបំណាច់ខ្ពង់ខ្ពស់ក្នុងការជួយឧបត្ថម្ភ ដល់វិស័យអប់រំជាតិក្នុងព្រះ រាជាណាចក្រកម្ពុជា ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា និង ប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញត្រូវអនុវត្តតាមអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អប្រសើរ ។

នាយករដ្ឋមន្ត្រីទី ១ **នាយករដ្ឋមន្ត្រីទី ២**

ព្រះហស្តលេខា និងត្រា **ហត្ថលេខា និង ត្រា**

នរោត្តម រណឫទ្ធិ **ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ១២៥ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ១៥ អនក្រ. ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ១៩៩៤ របស់រាជរដ្ឋាភិបាល ស្តីពីការបង្កើត និង ប្រើប្រាស់មេដាយស្ថាបនាជាតិ និង បណ្ណស្ថាបនាជាតិ
- តាមសំណើរបស់សកលវិទ្យាល័យភ្នំពេញ

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយស្ថាបនាជាតិថ្នាក់លេខ១ជូនចំពោះលោកបណ្ឌិត **សៃ មីងយូ** «TSAI MING YU» ប្រធានសមាគមវិភាគទានអន្តរជាតិ ដែលបានសាងសង់អាគារ សិក្សា ០១ ខ្នង មាន ០៣ ជាន់ ផ្តល់ជូនសកលវិទ្យាល័យភ្នំពេញអស់ទឹកប្រាក់ ៣០០.០០០ ដុល្លារអាមេរិក ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា ត្រូវអនុវត្តតាមអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១ **នាយករដ្ឋមន្ត្រីទី ២**

ព្រះហស្តលេខា និងត្រា **ហត្ថលេខា និង ត្រា**

នរោត្តម រណប្ញទ្ធិ ហ៊ុន សែន

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ១២៦ អនក្រ.តត

ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ២៨ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងអភិបាលរង ខេត្ត-ក្រុង
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : តែងតាំងលោក **ស៊ុ ហ្សាការីយ៉ា** ជាអភិបាលរងទី ៣ ខេត្តបាត់ដំបង ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋាន មុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងរដ្ឋលេខាធិការដ្ឋាន និង សាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	**នាយករដ្ឋមន្ត្រីទី ២**
ព្រះហស្តលេខា និងត្រា	**ហត្ថលេខា និង ត្រា**
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

២ - សេចក្តីសម្រេច

រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

សេចក្តីសម្រេចលេខ ៨០ សសរ

ស្តីពីការផ្ទេរសិទ្ធិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.១០៩៤/៨៤ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- តាមសំណើរបស់ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

សំរេច

ប្រការ ១ : ត្រូវបានផ្ទេរសិទ្ធិជូនឯកឧត្តម **ឃុ ហ៊ុកឡឺ** សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជារដ្ឋមន្ត្រីស្តីទីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្នុងឱកាស ដែល ឯកឧត្តម រដ្ឋមន្ត្រី **អ៊ុង ហួត** អញ្ជើញទៅបំពេញបេសកកម្មនៅបរទេស ចាប់ពីថ្ងៃទី ២០-១១-១៩៩៥ តទៅរហូតដល់ថ្ងៃឯកឧត្តម ត្រឡប់មកវិញ

ប្រការ ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការដ្ឋាន និង ឯកឧត្តម **ឃុ ហ៊ុកឡឺ** ត្រូវទទួលអនុវត្តសេចក្តីសំរេច ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	**នាយករដ្ឋមន្ត្រីទី ២**
ព្រះហស្តលេខា និងត្រា	**ហត្ថលេខា និង ត្រា**
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

*

រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

សេចក្តីសំរេចលេខ ៨១ សសរ

ស្តីពីការផ្ទេរសិទ្ធិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- តាមសំណើរបស់រដ្ឋលេខាធិការកិច្ចការនារី

សំរេច

ប្រការ ១ : ត្រូវបានផ្ទេរសិទ្ធិជូនឯកឧត្តម **ឌួច គាន់ឌុន** រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ជារដ្ឋលេខាធិការស្តីទីនៃរដ្ឋលេខាធិការដ្ឋានកិច្ចការនារី ជំនួសឯកឧត្តម **កៀត សុគន្ធ** ដែលបានច្បាប់ឈប់សំរាកព្យាបាលជម្ងឺ ចាប់ពីថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ រហូតដល់ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ១៩៩៥ ។

ប្រការ ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីគ្រប់ក្រសួង រដ្ឋលេខាធិការគ្រប់រដ្ឋលេខាធិការ ដ្ឋាននិង ឯកឧត្តម **ឌួច គាន់ឌុន** ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះ តាមភារកិច្ច រៀងៗខ្លួន ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	**នាយករដ្ឋមន្ត្រីទី ២**
ព្រះហស្តលេខា និងត្រា	**ហត្ថលេខា និង ត្រា**
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

សេចក្តីសំរេច លេខ ៨២ សសរ

ស្តីពីការបង្កើតគណៈកម្មការពិគ្រោះ ពិភាក្សាការផ្ទេរឯកជនភាវូបនីយកម្មចំការកៅស៊ូដប់ និង ក្រុមហ៊ុនជាមួយភាគី Terres Rouges

* * *

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា លេខ នស.រកត ១០៩៤.៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល

- បានឃើញ PROTOCOLE D' INTENTION ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៥ នៅទីក្រុងប៉ារីស
- យោងតាមសំណើរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ លេខ ៧០៥០ ចុះថ្ងៃទី ២៤-១១-៩៥

សំរេច

ប្រការ ១ : បង្កើតគណៈកម្មការអន្តរក្រសួងមួយ ដែលមានសមាសភាពដូចខាងក្រោម :

១-ឯកឧត្តម	**តាវ សែងហួរ**	រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់និង នេសាទ	ជាប្រធាន
២-ឯកឧត្តម	**ឆាយ ថន**	អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ	ជាអនុប្រធាន
៣-ឯកឧត្តម	**ហេង ចន់ម៉ុនឆាត**	ក្រុមប្រឹក្សាអ្នកច្បាប់	ជាសមាជិក
៤-លោក	**តេង ឡៅ**	អគ្គនាយកចំការកៅស៊ូ	ជាសមាជិក
៥-លោក	**លី ផលា**	អគ្គនាយករងចំការកៅស៊ូ	ជាសមាជិក
៦-លោក	**ហ៊ាង ឈាងចំណង**	អនុប្រធាននាយកដ្ឋានទ្រព្យសម្បត្តិ	ជាសមាជិក
៧-លោក	**ភុត សុខគីម**	ទីប្រឹក្សាក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ	ជាសមាជិក
៨-លោក	**ជូ ទិចិត្ត**	មន្ត្រីខុទ្ទកាល័យ	ជាសមាជិក

ប្រការ ២ : គណៈកម្មការនេះមានភារកិច្ចពិគ្រោះពិភាក្សា ជាមួយភាគីក្រុមដីក្រហម (Terres Rouges)ពីបញ្ហាដំណើរការធ្វើឯកជនភាវូបនីយកម្ម ចំការកៅស៊ូជប់ និង ក្រែក ។

ប្រការ ៣ : ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ មានសិទ្ធិប្រើប្រាស់ត្រាបស់ក្រសួងផ្ទាល់ ដើម្បីបំពេញភារកិច្ចនេះ ។

ប្រការ ៤ : សមាជិកទាំងអស់ ត្រូវចូលរួមធ្វើការតាមការអញ្ជើញ របស់ប្រធានគណៈកម្មការ ។

ប្រការ ៥ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ ប្រធានស្ថាប័នពាក់ព័ន្ធ និង ឯកឧត្តម

លោកដូចមានឈ្មោះក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសំរេចនេះតាមភារកិច្ចរៀង ៗ ខ្លួន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានិង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	**នាយករដ្ឋមន្ត្រីទី ២**
ព្រះហស្ថលេខា និងត្រា	**ហត្ថលេខា និង ត្រា**
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

III - ការិយាល័យក្រសួង

១ - ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ប្រកាស

រាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

ប្រកាសលេខ ៣៩២ ប្រក.សហវ.ថ

ស្តីពីការបង្វែរធនាគារ

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណា ព្រះបាទសម្តេច **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ ០១ នស ៩៣ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់គ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសឲ្យប្រើ

ដោយព្រះរាជក្រម លេខ ១០ នស ៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤

- បានឃើញច្បាប់ស្តីពីការកែតម្រូវ នៃច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ជស/រកម/០៩៩៥/០១ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៩៥
- បានឃើញអនុក្រឹត្យរបស់រាជរដ្ឋាភិបាលលេខ ៧៤ អនក្រ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបែងចែកឥណទានតាមជំពូកនៃច្បាប់ស្តីពីការកែតម្រូវ នៃច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥
- បានឃើញប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុលេខ ៣៣៨ ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបែងចែកឥណទាន ផ្ទៃក្នុងតាមជំពូក ប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ជូនបណ្តាក្រសួងតាមឥណទានចែងក្នុងច្បាប់ស្តីពីការកែតម្រូវនៃច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥
- បានឃើញប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ០០៦ ចុះថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការណែនាំអនុវត្តថវិកា ឆ្នាំ ១៩៩៥
- តាមសំណើរបស់ក្រសួងផែនការ លេខ ៣៣៧ ផ.ក ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ១៩៩៥ និង លេខ ៣៤៩ ផ.ក ចុះថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ១៩៩៥

សំរេច

ប្រការ ១ : ត្រូវបានប្រតិបត្តិនៅក្នុងរង្វង់ថវិការបស់ក្រសួងផែនការសំរាប់ការគ្រប់គ្រងថវិកា ឆ្នាំ ១៩៩៥ នូវការបង្វែរឥណទាន ដូចមានបញ្ជាក់ខាងក្រោមនេះ :

ឯកតា : ពាន់រៀល

ជំពូក	ប្រការ	កថាខ័ណ្ឌ	វាក្យខ័ណ្ឌ	ចំណាត់ថ្នាក់ចំណាយ	ស្ថានភាពឥណទានកែតម្រូវ	ការកែប្រែឥណទាន		ស្ថានភាពឥណទានថ្មី
						កើន	ថយ	
				ការបង្វែរពីជំពូក ១១			១៤.០០០	
១១	០១	០២		ចលនវត្ថុ និង សំភារៈ	៣៣.០០០	–	៣.០០០	៣០.០០០
១១	០១	០៤		គ្រឿងសំអាតពុម្ព និង សំភារៈ	៥៣.០០០	–	៧.០០០	៤៦.០០០

១១	០១	០៧	០១	ការថែទាំនិងដំណើរការ	២៥.០០០	–	៤.០០០	២១.០០០
				ផលប្រយោជន៍ជំពូក១១		១៥.០០០		
១១	០១	០៣		សោហ៊ុយតមនាគមន៍	២៥.៧០០	៦.០០០	–	៣១.៧០០
				ទូរស័ព្ទគឡិច				
១១	០២	០២	០២	សោហ៊ុយបេសកកម្ម	៤២.៥០០	៨.០០០	–	៥០.៥០០
				ក្រៅប្រទេស				
				ការបង្វែរតើជំពូក ៣១			៤៤៤	
៣១	[illegible]	[illegible]	[illegible]	[illegible]	[illegible]		៤៤៤	៥.៧៥៦
				[illegible]				
				ផលប្រយោជន៍ជំពូក៣១		[illegible]		
៣១	០១	[illegible]	[illegible]	[illegible]	–	៣៨៤	–	៣៨៤
៣១	០១	០១	[illegible]	[illegible]	–	៦០	–	៦០

ប្រការ ២ : ឯកឧត្តមរដ្ឋមន្ត្រីក្រសួងផែនការ[illegible]អនុវត្តប្រកាសនេះ
ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

អនុរដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

[illegible]

* * *

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

ប្រកាសលេខ ៣៩២ ប្រក.សហវ.ថ

ស្តីពីការបង្វែរឥណទាន

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

* * *

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណា ព្រះបាទសម្តេច **នរោត្តម សីហនុ** វរ្ម័ន ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១ នស ៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ១០ នស ៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ស្តីពីការកែតំរូវ នៃច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ជស/រកម/០៩៩៥/០១ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៩៥ ស្តីពីការបែងចែងឥណទាន ផ្ទៃក្នុងតាមជំពូក ប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ជូនបណ្តាក្រសួងតាមឥណទានចែងក្នុងច្បាប់ ស្តីពីការកែតំរូវ នៃច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥
- បានឃើញអនុក្រឹត្យរបស់រាជរដ្ឋាភិបាលលេខ ៧៤ អនក្រ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបែងចែកឥណទានតាមជំពូកនៃច្បាប់ស្តីពីការកែតំរូវ នៃច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥
- បានឃើញអនុក្រឹត្យរបស់រាជរដ្ឋាភិបាលលេខ ៧៨ អនក្របក ចុះថ្ងៃទី ១២ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបែងចែកចំណាយឥតគ្រោងទុក
- បានឃើញប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុលេខ ៣៣៨ ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបែងចែកឥណទាន ផ្ទៃក្នុងតាមជំពូក ប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ជូនបណ្តាក្រសួងតាមឥណទានចែងក្នុងច្បាប់ស្តីពីការកែតំរូវនៃច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥
- បានឃើញប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ០០៦ ចុះថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការណែនាំអនុវត្តថវិកា ឆ្នាំ ១៩៩៥
- តាមសំណើរបស់ក្រសួងផែនការ លេខ ២៦៧ លស.ផក ចុះថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ១៩៩៥ និងលេខ ៣០៦ លស.ផក ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៩៥

សំរេច

ប្រការ ១ : ត្រូវបានផ្តល់ឥណទានបន្ថែមក្នុងសៀវភៅថវិកាសំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥ របស់ក្រសួងផែនការចំនួន ហាសិបប្រាំបួនលានរៀលគត់ (៥៩.០០០.០០០រៀល) ដោយបែងចែកនៅក្នុងជំពូក ១១ តាមប្រការ កថាខ័ណ្ឌ វាក្យខ័ណ្ឌ ដូចតទៅ :

ជំពូក	ប្រការ	ថកា ខ័ណ្ឌ	វាក្យ ខ័ណ្ឌ	ចំណាត់ថ្នាក់ ចំណាយ	ឥណទាន កែតំរូវ	ឥណទានផ្តល់ បន្ថែម	ស្ថានភាព ឥណទានថ្មី
១១	០១	០៨	០១	សោហ៊ុយសំរាប់ ទទួលភ្ញៀវបរទេស	៨.៦០០.០០០	៥៩.០០០.០០០	៦៧.៦០០.០០០

ប្រការ ២ : ឯកឧត្តមរដ្ឋមន្ត្រីក្រសួងផែនការជាអ្នកទទួលបន្ទុកអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

អនុរដ្ឋលេខាធិការ

ឧត្តមលេខា និង ត្រូវ

នាយ ច័ន

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

ប្រកាសលេខ ៤១៥ ប្រក.សហវ.ថ

ស្តីអំពីការបង្វែរឥណទាន

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

* * *

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ .
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១ នស ៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១០ នស ៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ស្តីពីការកែតំរូវ នៃច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ជស/រកម/០៩៩៥/០១ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៩៥
- បានឃើញអនុក្រឹត្យរបស់រាជរដ្ឋាភិបាលលេខ ៧៤ អនក្រ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបែងចែកឥណទាន តាមជំពូកនៃច្បាប់ស្តីពីការកែតំរូវ នៃច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥ .
- បានឃើញប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ លេខ ៣៣៨ ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបែងចែកឥណទានផ្ទៃក្នុងតាមជំពូក ប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ជូនបណ្តាក្រសួងតាមឥណទានចែងក្នុងច្បាប់ ស្តីពីការកែតំរូវនៃច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥ .
- បានឃើញប្រកាសរបស់ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ លេខ ០០៦ ចុះថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ១៩៩៥ ស្តីពីការណែនាំអនុវត្តថវិកា ឆ្នាំ ១៩៩៥ .
- តាមសំណើរបស់ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ លេខ ៣០៦ សណ ផត ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ .

សំរេច

ប្រការ ១ : ត្រូវបានប្រតិបត្តិនៅក្នុងរង្វង់ថវិការបស់ក្រសួង វប្បធម៌ និង វិចិត្រសិល្បៈ សំរាប់ការគ្រប់គ្រងថវិកា ឆ្នាំ ១៩៩៥ នូវការបង្វែរឥណទានដូចមានបញ្ជាក់ខាងក្រោមនេះ :

ឯកតា : ពាន់រៀល

ជំពូក	ប្រការ	កថាខ័ណ្ឌ	វាក្យខ័ណ្ឌ	ចំណាត់ថ្នាក់ចំណាយ	ស្ថានភាពឥណទានកែតំរូវ	ការកែប្រែឥណទាន		ស្ថានភាពឥណទានថ្មី
						កើន	ថយ	
១១	០១	១៤	០៣	ការបង្កើតជំពូក ១១ ទស្សនីយភាព និង ពិព័រណ៍	៩៧៣.០០០	–	៣០.០០០ ៣០.០០០	៩៤៣.០០០
១១	០១	០៧	០២	ផលប្រយោជន៍ជំពូក១១ ប្រេងឥន្ធនៈនិង ប្រេងរំអិល	១២០.០០០	៣០.០០០ ៣០.០០០	–	១៥០.០០០

ប្រការ ២ : ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ជាអ្នកទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

អនុរដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

នាយ ខន

* * *

២ - ទីស្តីការរដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

ប្រកាស

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

ប្រកាសលេខ ៨៣៦ ឧក.ប្រក

ប្រការ ១ : អនុញ្ញាតអោយសហគ្រាសផលិតគ្រឿងសម្អាង ដែលមានលោក **ឈុន អេង** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០០៥៩៩៥ ក.ប ចុះថ្ងៃទី ២៨_០១_៨៦ ជា ប្រធាន អាស័យដ្ឋានបច្ចុប្បន្ន ភូមិមេមត់ ឃុំមេមត់ ស្រុកមេមត់

ខេត្តកំពង់ចាម បើកដំណើរការផលិតកម្ម នៅក្នុងទីតាំង ផ្លូវជាតិលេខ ៧ ភូមិជ្រាំទ្រៀក ឃុំត្រមូង ស្រុកមេមត់ ខេត្តកំពង់ចាម ។

ប្រការ ២ : លោក **ឈុន អេង** ត្រូវចាប់ផ្តើមដំណើរការផលិតកម្ម លើទីតាំងដូចបានកំណត់ក្នុងប្លង់ ក្នុងរយៈពេល ០៦ ខែ គិតចាប់តាំងពីថ្ងៃដែលបានចុះហត្ថលេខា លើប្រកាសនេះ ។ ហួសកាលកំណត់ប្រកាសនេះ ត្រូវចាត់ទុកជាមោឃៈ ។

ប្រការ ៣ : ក្នុងកិច្ចដំណើរការផលិតកម្ម ម្ចាស់សហគ្រាសត្រូវធានាសុវត្ថិភាពឧស្សាហកម្ម ធានាបរិដ្ឋាន ធានាគុណភាពផលិតផល ព្រមទាំងត្រូវគោរពរាល់ច្បាប់និងបទបញ្ញត្តិដែលមានជាធរ មាន ។

ប្រការ ៤ : សហគ្រាសនេះត្រូវបានអនុញ្ញាតអោយផលិតនូវមុខផលិតផលជាសារវន្តៈ ឈើការ៉ូ គ្រឿង តុ ទូ ទ្វារ បង្អួច បង្កាន់ដៃជណ្តើរ និង ឈើកៅស៊ូជ្រុង ។ វត្ថុធាតុដើមដែលយកមកប្រើ ប្រាស់ក្នុងផលិតកម្ម គឺឈើដែលមានលក្ខណៈស្របច្បាប់ ដែលសាមីម្ចាស់សហគ្រាសត្រូវ រ៉ាប់រងដោះស្រាយដោយខ្លួនឯង ។

ប្រការ ៥ : ម្ចាស់សហគ្រាសត្រូវជូនដំណឹងមកក្រសួងតាមរយៈមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្តកំពង់ចាម អំពីកាលបរិច្ឆេទនៃការចាប់ផ្តើមដំណើរការ ជាផ្លូវការ និង ផ្ញើរបាយការណ៍ ប្រចាំខែ អំពីសកម្មភាពផលិតកម្ម របស់សហគ្រាស ។

ប្រការ ៦ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់សហគ្រាសត្រូវធ្វើ ពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិដ្ឋានប្រកាសនេះ នឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

ប្រកាសលេខ ៨៣៨ ឧក. ប្រក.

ប្រការ ១ : អនុញ្ញាតអោយលោក **ស៊្រុន ម៉ែរ** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ៣៦៤២៨៨ ភ.ព ចុះថ្ងៃទី ១១_០១_៩៣ អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ ៧៥៣ ផ្លូវអាចារ្យ មៀន សង្កាត់បឹងប្រលិត ខណ្ឌចំការមនរាជធានីភ្នំពេញ បើក

ដំណើរការរោងជាង ផលិតគ្រឿងសង្ហារឹម នៅក្នុងទីតាំងភូមិ ត្បែស ឃុំ វល្លិស ស្រុក សំរោងទង ខេត្តកំពង់ស្ពឺ។

ប្រការ ២ : លោក **ស្រ៊ុន ហ៊ិន** ត្រូវចាប់ផ្តើមដំណើរការផលិតកម្ម លើទីតាំងដូចបានកំណត់ក្នុងប្លង់ ក្នុងរយៈពេល ០៦ ខែ គិតចាប់តាំងពីថ្ងៃដែលបានចុះហត្ថលេខាលើប្រកាសនេះ ។ ហួសកាលកំណត់ប្រកាសនេះ ត្រូវចាត់ទុកជាមោឃៈ ។

ប្រការ ៣ : ក្នុងកិច្ចដំណើរការផលិតកម្ម ម្ចាស់រោងជាងត្រូវធានាសុវត្ថិភាពឧស្សាហកម្ម ធានាបរិដ្ឋាន ធានាគុណភាពផលិតផល ព្រមទាំងត្រូវគោរពរាល់ច្បាប់ និង បទបញ្ញត្តិដែលមានជាធរមាន ។

ប្រការ ៤ : រោងជាងនេះ ត្រូវបានអនុញ្ញាតអោយផលិតនូវមុខផលិតផលជាសារវន្តៈ ការ៉ូឈើ តុ ទូ កៅអី ទ្វារ បង្អួច និងពិដានឈើ ។ វត្ថុធាតុដើមដែលយកមកប្រើប្រាស់ក្នុងផលិតកម្ម គឺ ឈើដែលមានលក្ខណៈស្របច្បាប់ ដែលសាមីរោងជាង ត្រូវរករងដោះស្រាយដោយខ្លួនឯង ។

ប្រការ ៥ : ម្ចាស់រោងជាងត្រូវជូនដំណឹងមកក្រសួងតាមរយៈមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលខេត្ត កំពង់ស្ពឺ អំពីកាលបរិច្ឆេទនៃការចាប់ផ្តើមដំណើរការជាផ្លូវការ និងផ្ញើរបាយការណ៍ប្រចាំ ខែអំពីសកម្មភាពផលិតកម្មរបស់រោងជាង ។

ប្រការ ៦ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បី ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់រោងជាងត្រូវធ្វើ ពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិដ្ឋាន ប្រកាសនេះនឹងត្រូវដកហូតវិញ ដោយគ្មានសំណងឡើយ ។

* * *

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

ប្រកាសលេខ ៨៤០ ឧក. ប្រក.

ប្រការ ១ : អនុញ្ញាតអោយលោក **សុខ ឈួរ** ម្ចាស់ឡផលិតឥដ្ឋ-ក្បឿង ដែលមានទីតាំងនៅភូមិដំណាក់សង្កែ ឃុំព្រែកកំពឹស ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ផ្ទេរកម្មសិទ្ធិគ្រប់គ្រងជូន អ្នកស្រី **សាមីឌី ស្វលីនដា** វិញ ។

ប្រការ ២ : ទទួលស្គាល់អ្នកស្រី **សាមីឌី សុលីនដា** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ៣៨៦៩២៩ ភព. ចុះថ្ងៃទី ០៨-១០-១៩៩២ អាស័យដ្ឋានបច្ចុប្បន្នផ្ទះលេខ ៤០ សេ ផ្លូវលេខ ៩៥ សង្កាត់បឹងកេងកង ៣ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ ជាអ្នកគ្រប់គ្រងឡផលិតឥដ្ឋ-ក្បឿង ដែលមានទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ ៣ : អនុញ្ញាតអោយអ្នកស្រី **សាមីឌី សុលីនដា** ពង្រីកបន្ថែមផលិតកម្មរោងជាងផលិតគ្រឿងសង្ហារឹម យីហោ "KIANG TECHATATIWONG PROCESSING WOOD IMP & EXP Co.LTD " នៅក្នុងបរិវេណទីតាំងឡផលិតឥដ្ឋក្បឿង ។

ប្រការ ៤ : អ្នកស្រី **សាមីឌី សុលីនដា** ត្រូវចាប់ផ្តើមរៀបចំរោងជាងផលិតគ្រឿងសង្ហារឹមរបស់ខ្លួន អោយស្រេចជាស្ថាពរ ក្នុងរយៈពេល ០៦ ខែ គិតចាប់តាំងពីថ្ងៃដែលបានចុះហត្ថលេខាលើ ប្រកាសនេះ ។

ប្រការ ៥ : ក្នុងកិច្ចដំណើរការផលិតកម្ម អ្នកស្រី **សាមីឌី សុលីនដា** ត្រូវធានាសុវត្ថិភាពឧស្សាហកម្ម ធានាបរិដ្ឋាន ធានាគុណភាពផលិតផល ព្រមទាំងត្រូវ គោរពរាល់ច្បាប់ និងបទបញ្ញត្តិ ដែលមានជាធរមាន ។

ប្រការ ៦ : រោងជាងនេះត្រូវបានអនុញ្ញាតអោយផលិតនូវមុខផលិតផលជាសារវន្ត តុ ទូ កៅអី ទ្វារ កាវ៉ូពិដាន ទ្រុងរថយន្ត និងចាន់ខ្យែត ។ វត្ថុធាតុដើមដែលយកមកប្រើប្រាស់ក្នុងផលិតកម្ម គឺឈើដែលមានលក្ខណៈស្របច្បាប់ ដែលសាមីរោងជាងត្រូវរ៉ាប់រងដោះស្រាយដោយខ្លួនឯង ។

ប្រការ ៧ : ម្ចាស់រោងជាងត្រូវជូនដំណឹងមកក្រសួងតាមរយៈមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលខេត្ត កណ្តាល អំពីកាលបរិច្ឆេទ នៃការចាប់ផ្តើមដំណើរការជាផ្លូវការ និងធ្វើរបាយការណ៍ប្រចាំខែ អំពីសកម្មភាពផលិតកម្មរបស់រោងជាង ។

ប្រការ ៨ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បី ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់រោងជាងត្រូវធ្វើ ពាក្យសុំការអនុញ្ញាត បន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិដ្ឋាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

ប្រការ ៦: ប្រកាសលេខ ២៨៤ ឧក.ប្រកចុះថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ១៩៩៤ ត្រូវចាត់ទុកជានិរាករណ៍ ។

* * *

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

ប្រកាសលេខ ៨៥២ ឧក.ប្រក.

ប្រការ ១: អនុញ្ញាតអោយ CITY NEW GARMENT FACTORY (CAMBODIA) Co. LTD តំណាងអោយលោក **ឈុង ឆុកហ៊ុង** (Mr. CHONG CHOK HUNG) ជនជាតិ ចិន ហុងកុង អាស័យដ្ឋាន Flat C4/F Wing Hing. Ind Bldg 499 Castle Peak Road Kow Poon កាន់លិខិតឆ្លងដែនលេខ B ៣៨៨១៥៧ (៣). ចេញថ្ងៃទី ២៣_០៨_៩៣ ដំណើរការផលិតកម្ម_អាជីវកម្ម រោងចក្រកាត់ដេរសំលៀកបំពាក់សំរាប់នាំចេញដែលមានឈ្មោះថា :CITY NEW GARMENT FACTORY (CAMBODIA) មានទីតាំងនៅ អតីតរោងចក្រជួសជុលកង់រថយន្ត (S K P) ផ្លូវលេខ ៦៨ សង្កាត់ស្រះចក ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ ។

ប្រការ ២: រោងចក្រ ត្រូវដំណើរការផលិតកម្មតាមគំរោង របាយការណ៍ បច្ចេកទេសសេដ្ឋកិច្ច ចុះថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៤ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល លើទីតាំងដែលបានកំណត់ក្នុងប្លង់គិតចាប់ពីថ្ងៃដែលបានចុះហត្ថលេខា លើប្រកាសនេះ ។

ប្រការ ៣: សាមីក្រុមហ៊ុនត្រូវធ្វើរបាយការណ៍ប្រចាំខែអំពីសកម្មភាព ផលិតកម្ម_អាជីវកម្ម ជូនក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ ៤: ក្នុងកិច្ចដំណើរការ ក្រុមហ៊ុនត្រូវធានាសុវត្ថិភាព ឧស្សាហកម្ម ធានាការពារបរិដ្ឋាន និង ធានាគុណភាពផលិតផល ព្រមទាំងត្រូវគោរពច្បាប់ និង បទបញ្ញត្តិដែលមានជាធរមាន ។

ប្រការ ៥: សាមីក្រុមហ៊ុន ត្រូវផលិតចេញនូវ " សម្លៀកបំពាក់គ្រប់ប្រភេទ " ទៅតាមគំរូ និងផ្លាកសញ្ញា ដែលតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ ៦ : ក្នុងករណីប្រព្រឹត្តល្មើសនឹងប្រការណាមួយដែលបានចែងខាងលើ ប្រកាសនេះអាចដកហូតវិញ ដោយគ្មានការតវ៉ាឡើយ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ពូ សុធីរ:

* * *

៣ - ទីស្ដីការរដ្ឋមន្ត្រីក្រសួងពត៌មាន

ប្រកាស

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

ប្រកាសលេខ ២៩០/៩៥ ពម.ប្រក.

អនុញ្ញាតអោយលោក ម៉ិយ កោសល្យ បើកអាជីវកម្ម

រោងពុម្ពឈ្មោះ «ពន្លឺស្មើ»

រដ្ឋមន្ត្រីក្រសួងពត៌មាន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣
- យោងលិខិតជូនដំណឹងរបស់ក្រសួងពត៌មានលេខ ១២២៤.៩៤ ពម. ចុះថ្ងៃទី ១៤-១១-៩៤ ស្ដីពីការបោះពុម្ពផ្សាយ
- យោងលិខិតស្នើសុំអនុញ្ញាតច្បាប់ បើកអាជីវកម្មរោងពុម្ពឈ្មោះ «ពន្លឺស្មើ» របស់លោក ម៉ិយ កោសល្យ ចុះថ្ងៃទី ១១-១១-៩៥

សំរេច

ប្រការ ១ : អនុញ្ញាតជូនលោក ម៉ិយ កោសល្យ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ៨ អាអ៊ី.២ ផ្លូវលេខ ១៤១ សង្កាត់បឹងព្រលឹត ខ័ណ្ឌ ៧ មករា ក្រុងភ្នំពេញ បើកអាជីវកម្ម

ពេងពុម្ពដែលមានផ្លាកយីហោ ឈ្មោះ " ពន្លឺរស្មី " ស្ថិតនៅផ្ទះលេខ ១១ អ៊ី.០ ផ្លូវលេខ ១៧២ សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ ក្រុងភ្នំពេញ ។

ប្រការ ២ : រាល់ដំណើរការបោះពុម្ពផ្សាយលោក **ម៉ឺយ កោសល្យ** ត្រូវអនុវត្តអោយបានល្អ តាម កិច្ចសន្យា សមស្រប រក្សាបាននូវទំនៀមទំលាប់ សន្តិសុខសណ្តាប់ធ្នាប់សង្គម និងច្បាប់ របស់ព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ៣ : ក្នុងករណីប្រព្រឹត្តល្មើស ដូចមានចែងក្នុងប្រការ ២ សាមីខ្លួននឹងត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៤ : នាយកដ្ឋានគ្រប់គ្រងការបោះពុម្ពផ្សាយ_សោតទស្សន៍ នៃអគ្គនាយកដ្ឋាន រដ្ឋបាល និងហិរញ្ញវត្ថុ ប្រធានមន្ទីរពត៌មានរាជធានីភ្នំពេញ ត្រូវទទួលអនុវត្តតាមប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ។

ប្រការ ៥ : ប្រកាសនេះ មានអានុភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ខៀវ កាញារីទ្ធ

៤ - ទីស្តីការរដ្ឋមន្ត្រីក្រសួងផែនការ

ប្រកាស

ភ្នំពេញ, ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

ប្រកាស លេខ ១២៨ ផក

ស្តីអំពីការបង្កើតការិយាល័យវិនិយោគសាធារណៈ

រដ្ឋមន្ត្រីក្រសួងផែនការ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញភាពចាំបាច់របស់ក្រសួង៖

សំរេច

ប្រការ ១ : បង្កើតការិយាល័យកម្មវិធីវិនិយោគសាធារណៈ ដែលស្ថិតនៅក្រោមឱវាទរបស់នាយកដ្ឋានវិនិយោគសាធារណៈ ។

ប្រការ ២ : តួនាទីរបស់ការិយាល័យនេះមានដូចតទៅ ÷

-ទំនាក់ទំនង និងសំរបសំរួលជាមួយបណ្តាក្រសួង ស្ថាប័ន ខេត្ត ក្រុង ដើម្បីប្រមូលចងក្រង វាយតំលៃ និងកំណត់អាទិភាពលើរាល់គំរោងវិនិយោគ សាធារណៈអោយបានសមស្រប តាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ។

-រក្សាទិន្នន័យមូលដ្ឋាន របស់កម្មវិធីវិនិយោគសាធារណៈ ។

-ទំនាក់ទំនងជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីធានានូវការផ្តល់ទុនរបស់រាជរដ្ឋាភិបាល ចំពោះគំរោងដែលបានអនុម័តរួច ។

-ទំនាក់ទំនងជាមួយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាអំពីបញ្ហាដែលទាក់ទងទៅនឹងអង្គការផ្តល់ជំនួយសំរាប់គំរោង ។

-រៀបចំឯកសារ ស្តីពីកម្មវិធីវិនិយោគសាធារណៈរយៈពេល ៣ ឆ្នាំ ដែលត្រូវរំកិលរៀងរាល់ឆ្នាំ អោយស្របទៅតាមផែនការជាតិរយៈពេល ៥ ឆ្នាំ ដើម្បីដាក់ជូនរាជរដ្ឋាភិបាល ។

-មានភារកិច្ចតាមដានលើការផ្តល់ទុននិងការអនុវត្តន៍គំរោងរបស់បណ្តាក្រសួង ស្ថាប័ន ខេត្ត ក្រុង ។

-ទទួលខុសត្រូវលើការងារផ្សេងទៀតដែលពាក់ព័ន្ធទៅនឹងការរៀបចំកម្មវិធីវិនិយោគសាធារណៈ ។

ប្រការ ៣ : លោកប្រធានមន្ទីរ លោកប្រធាននាយកដ្ឋានវិនិយោគសាធារណៈ លោកប្រធានអង្គភាព ដែលមានការពាក់ព័ន្ធ មានភារកិច្ចរៀងៗខ្លួនអនុវត្ត តាមប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខា នេះតទៅ ។

ហត្ថលេខា និង ត្រា

ជា ចាន់តូ

* * *

៥ - ទីស្តីការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

ប្រកាស

ភ្នំពេញ, ថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

ប្រកាស លេខ : ១៧៥ បន. ប្រក

ស្តីពីថ្លៃប្រើប្រាស់បរិមាណទិន្នន័យក្នុងប្រទេស

* * *

រដ្ឋលេខាធិការ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ចុះថ្ងៃទី ០១ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ ចុះថ្ងៃទី ០៥-៣-៨៧ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្តីអំពី ប្រៃសណីយ៍ និងទូរគមនាគមន៍ ។
- បានឃើញសេចក្តីសំរេចលេខ ១៥៥ សសរ ចុះថ្ងៃទី ១១-១២-៩១ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្តីពីហេតុក្រមគ្រប់គ្រងតំលៃ ។

សំរេច

ប្រការ ១ : កំណត់ថ្លៃប្រើប្រាស់ទិន្នន័យ ក្នុងប្រទេសដូចមានចែងក្នុងតារាងខាងក្រោមនេះ ។

ប្រការ ២ : ប្រកាសទាំងឡាយណាដែលចេញពីមុនហើយ មានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៣ : ខុទ្ទកាល័យ អធិការដ្ឋាន នាយកដ្ឋានផែនការគណនេយ្យ និងហិរញ្ញកិច្ច នាយកដ្ឋានទូរគមនាគមន៍ ក្នុងប្រទេស នាយកដ្ឋានទូរគមនាគមន៍អន្តរជាតិ និងនាយកដ្ឋានប្រៃសណីយ៍ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ ។

ប្រការ ៤ : ប្រកាសនេះ មានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

តារាង

បរិបទក្នុងទីក្រុងមួយ		
	ថ្លៃក្នុង ១ ខែ	ថ្លៃស្ថាបនា
បំរើដោយខ្សែកាបមួយគូ (2-Wire)	$ 150	$ 200
បំរើដោយខ្សែកាបពីរគូ (4-Wire)	$ 225	$ 300
បំរើដោយប្រព័ន្ធវិទ្យុ	(កំណត់ជាក្រោយ)	
បរិបទពីទីក្រុងមួយ ទៅទីក្រុងមួយ	(កំណត់ជាក្រោយ)	

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ស៊ុ ឃុន

បោះពុម្ពនៅរោងពុម្ពទីស្តីការគណៈរដ្ឋមន្ត្រី
លើកទី ១ ចំនួន ២៨០០ ច្បាប់

[illegible]